# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣១ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការតែងតាំងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- ព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា

## សម្រេច

**ប្រការ ១.-**

សេចក្តីសម្រេចនេះ មានគោលដៅដាក់ឱ្យអនុវត្ត «គោលការណ៍ណែនាំអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ» ប្រកបដោយប្រសិទ្ធភាព សំដៅដល់ការចូលរួមអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ ឱ្យក្លាយជាផលិតផលទេសចរណ៍ប្រកបដោយគុណភាព សុវត្ថិភាព និងនិរន្តរភាព។

**ប្រការ ២.-**

សេចក្តីសម្រេចនេះមានគោលបំណង ដូចតទៅ ៖

- ផ្តល់ដល់អ្នកអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រនូវឧបករណ៍ឯកសារជំនួយដល់ការរៀបចំផែនការមេអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្ររបស់ខ្លួនប្រកបដោយ គុណភាព ការទទួលខុសត្រូវ និង និរន្តរភាពផ្អែកបរិស្ថាន សេដ្ឋកិច្ច និងសង្គម។
- ផ្តល់នូវឯកសារណែនាំដល់ការរៀបចំផែនការគ្រប់គ្រងទេសចរណ៍ឆ្នេរសមុទ្រនីមួយៗ សំដៅធានាបានគុណភាពសេវាកម្ម សុវត្ថិភាពទេសចរនៅតាមឆ្នេរសមុទ្រ ដោយផ្តោតសំខាន់លើការអប់រំ ការផ្តល់ព័ត៌មាន និងការគ្រប់គ្រងបរិស្ថាន សុវត្ថិភាព សេវាកម្ម និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបៃតងប្រកបដោយគុណភាព និងឆ្លើយតបចំពោះគោលការណ៍ទប់ស្កាត់ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការរៀបចំដែនដី និងនគរូបនីយកម្ម ព្រមទាំងជំរុញស្មារតីចូលរួមរបស់ប្រតិបត្តិករទេសចរណ៍ ក្នុងអភិបាលកិច្ចល្អលើបរិស្ថាន អនាម័យតំបន់ឆ្នេរសមុទ្រកម្ពុជា ។

**ប្រការ ៣.-**

រាល់គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ត្រូវបានបែងចែកជា ៥ (ប្រាំ) ប្រភេទ រួមមាន ៖

- ប្រភេទទី១: រមណីយដ្ឋានឆ្នេរអភិរក្សស្ងួល
- ប្រភេទទី២: រមណីយដ្ឋានឆ្នេរអេកូទេសចរណ៍
- ប្រភេទទី៣: រមណីយដ្ឋានឆ្នេរកម្សាន្តបែបប្រណិត
- ប្រភេទទី៤: រមណីយដ្ឋានឆ្នេរកម្សាន្តសាធារណៈកម្រិតខ្ពស់
- ប្រភេទទី៥: រមណីយដ្ឋានឆ្នេរកម្សាន្តសាធារណៈកម្រិតមធ្យម។

លក្ខណវិនិច្ឆ័យ និងវិសាលភាពនៃប្រភេទរមណីយដ្ឋានឆ្នេរសមុទ្រនីមួយៗ មានចែងក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

**ប្រការ ៤.-**

រាល់ការអភិវឌ្ឍរមណីយដ្ឋានឆ្នេរសមុទ្រ ត្រូវធ្វើឡើងក្រោមទម្រង់នៃការអភិវឌ្ឍ និងគ្រប់គ្រងដោយរដ្ឋ ឬដោយរដ្ឋនិងឯកជន ឬដោយសហគមន៍ រដ្ឋ និងឯកជន ដែលទម្រង់នៃការអភិវឌ្ឍនីមួយៗ ត្រូវកំណត់ក្នុងផែនការមេអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ។

**ប្រការ ៥.-**

រាល់ការរៀបចំសេចក្តីព្រាងផែនការមេអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រនីមួយៗ ត្រូវធ្វើឡើងដោយក្រុមហ៊ុនពិគ្រោះយោបល់ ដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា។

នីតិវិធី និងបែបបទការទទួលស្គាល់ក្រុមហ៊ុនពិគ្រោះយោបល់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ និងក្រសួងបរិស្ថាន។

**ប្រការ ៦._**

ផែនការមេអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ត្រូវពិនិត្យ និងសម្រេចដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា។

ផែនការមេអភិវឌ្ឍន៍រមណីយដ្ឋានឆ្នេរសមុទ្រ ត្រូវមានភ្ជាប់មកជាមួយនូវៈ

- ផែនការគ្រប់គ្រងទេសចរណ៍ ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន
- ប្លង់គោល និងផែនការប្រើប្រាស់ដី ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ប្រការ ៧._**

ប្រគល់ភារកិច្ចជូនគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជាធ្វើបច្ចុប្បន្នភាពឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះក្នុងករណីចាំបាច់។

**ប្រការ ៨._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធានគ្រប់ក្រសួង-ស្ថាប័ន អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៧...ខែ....៥.......ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ